Reçu le 25-6-51

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

...ណ្ណកាល័យ...
សាលអ...
C.078.2
ពុទ្ធសាសនបណ្ឌិត្យ

ឆ្នាំទី ២៣ ខែឧសភា លេខ ៥

ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រឹស្តសាសនា ( សន្និសីទលោកវេជ្ជបណ្ឌិតមីគូត ) (តមក) . . . | លោក ភិយ - ប៊ុក . . . . . . | ៣២៣ |
| ពន្លឺអាស៊ីទ្វីប (តមក) . . . . . . . . . . | លោក ភិយ - ប៊ុក . . . . . . | ៣២៨ |
| បភាកថា . . . . . . . . . . . . . . . . | អាចារ្យ ទោល - ជ្រាក់ . . . . . | ៣៣៤ |

ផ្នែកអក្សរសាស្ត្រ

| | | |
|---|---|---|
| សារលិខិតនៃលោកស្វាមីវិវេកានន្ទ (តចប់) | លោក ភិ - ប៊ុក . . . . . . . . | ៣៤២ |
| ការបណ្ដុះទីសង្ស័យ (តមក) . . . . . . . | ព្រះមហាឧត្ដមវិជ្ជា ប៊ុត - ប៉ម . . | ៣៤៧ |
| អ៊ីឡេណា - សំម្យ៉ូណា . . . . . . . . . . | លោកផេង - ជ្រីវ . . . . . . . | ៣៥៩ |
| សព្ទបារាំងប្រែជាខ្មែរ ( តមក ) . . . . . | លោក ម៉ុញ - តាំគ្រី . . . . . . . | ៣៦៨ |
| រឿងសាមកុក (តមក) . . . . . . . . . . | ឧកញ៉ា ឌូ - កន . . . . . . . . . | ៣៧៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . | – ឈឹម - ក្រសេម . . . . . | ៣៨៦ |

កំណត់ទិនប្រវត្តិការណ៍

| | | |
|---|---|---|
| ពិធីបុណ្យប្រគេនព្រហ្មទានចំពោះព្រះសង្ឃ ៩៨ រូប ដើលប្រឡងជាប់សញ្ញាបត្រ សាលាបាលីជាន់ខ្ពស់ (តចប់ . . . . . . . . . . . . | សមាគមមិត្តសាលាបាលី . . . . | ៣៩៣ |


មួយឆ្នាំមាន ១២ សៀវភៅ ជំឡៃជាវ . . . . . . . . . . . . . . ១៤៥ʳ,០០

## បាឋកថា

# លោកអាចារ្យ ខោល - ប្រាក់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាជាករវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៧ រោច ខែស្រាពណ៍
ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០ (៧-១០-៤៧)

---

### នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យដោយគោរព ។

បន្ទាប់អំពីបទនមស្ការនេះទៅ ខ្ញុំសូមសំដែងធម៌ទេសនាតាមសមគួរដល់កាលវេលា ។

ធម្មតាមនុស្សក្នុងលោក ច្រើនណាស់ចូលចិត្តភ្លឺ មិនសូវចូលចិត្តងងឹតទេ, ដោយហោចទៅ សូម្បីតែមនុស្សមានភ្នែកខ្វាក់ក៏ចូលចិត្តភ្លឺដែរ; ព្រោះពន្លឺអាចបំភ្លឺឲ្យមើលវត្ថុគ្រប់យ៉ាងបាន ។ ហេតុនោះ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាតថា: ពន្លឺនេះជាធម្មជាតិយ៉ាងប្រសើរវិសេសក្នុងលោក អាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចបាន ។

ពន្លឺនោះមាន ៤ យ៉ាង គឺ:

១ – ពន្លឺព្រះអាទិត្យ ;

២ – ពន្លឺព្រះចន្ទ្រ ;

៣ – ពន្លឺភ្លើង ;

៤ – ពន្លឺគឺប្រាជ្ញា ។

សូមអធិប្បាយអំពីពន្លឺទាំង ៤ នេះដោយសង្ខេបថា :

**ព្រះអាទិត្យ** មានអំណាចផ្ទុះពន្លឺឲ្យភ្លឺទៅដោយខ្លួនឯងបានតែក្នុងវេលាថ្ងៃប៉ុណ្ណោះ; មិនអាចផ្ទុះបំភ្លឺក្នុងវេលាយប់បានឡើយ ។

**ព្រះចន្ទ** មានអំណាចផ្ទុះពន្លឺឲ្យភ្លឺបានតែក្នុងវេលាយប់ប៉ុណ្ណោះ មិនអាចនឹងផ្ទុះបំភ្លឺក្នុងវេលាថ្ងៃបាន ។

**ភ្លើង** មានអំណាចផ្ទុះបំភ្លឺទៅបានតែក្នុងពេលដែលគេបង្កាត់ឬអុជប៉ុណ្ណោះ មិនអាចនឹងផ្សាយរស្មីឲ្យភ្លឺទៅក្នុងទីដទៃៗ បានឡើយ ។

បណ្ដាពន្លឺទាំង ៣ ដែលបានពណ៌នាមកនេះ នឹងបញ្ចេញពន្លឺរស្មីទៅបានតែទីណាដែលមានឱកាសល្មមប៉ុណ្ណោះ តែទីណាដែលជ្រៅកំបាំង ពន្លឺទាំង ៣ នេះមិនអាចនឹងផ្សាយទៅបាន ។

**បញ្ញា** ជាពន្លឺមួយវិសេសជាងពន្លឺទាំង ៣ នោះ ព្រោះអាចផ្ទុះបំភ្លឺទៅកាន់ទីឆ្ងាយឬទីជិត ទីជ្រៅឬទីកំបាំងបាន ។

តែស្ទង់សម្រាប់ស្ទង់នូវរបស់ឲ្យដឹងចំនួនថាប៉ុណ្ណោះប៉ុណ្ណោះយ៉ាងណា បញ្ញាសម្រាប់ថ្លឹងស្ទង់មើលហេតុការណ៍អាក្រក់ល្អបានទាំងអស់, មិនមានរើសតាលក៏យ៉ាងនោះដែរ; តួយ៉ាងដូចជាសម្បត្តិស្ថានសួគ៌ និងស្ថានព្រះនិព្វាន បើក្រៅតែអំពីបញ្ញាហើយ មិនអាចនឹងបញ្ចាំងបានឡើយ ។

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាជាតិណា សាសន៍ណា ឬភាសាណាទេ, សុទ្ធសឹងតែមានសេចក្ដីប្រាថ្នាចង់បានបញ្ញាគ្រប់ៗគ្នា ប៉ុន្តែសេចក្ដីប្រាថ្នានោះ ជួនកាលក៏បានសម្រេច ជួនកាលក៏មិនបានសម្រេច ព្រោះបុគ្គលខ្លះចង់បានបញ្ញា ហើយខំប្រឹងប្រែងបណ្ដុះផ្សាំពូជបញ្ញានោះឲ្យកើតឡើង បុគ្គលខ្លះចង់បានបញ្ញាដូចគេឯងដែរ ប៉ុន្តែជាមនុស្សខ្ជិលច្រអូស មិនខំប្រឹងប្រែងផ្សាំពូជបញ្ញានោះឲ្យកើតឡើងទឹងគេទេ ។

ហេតុនាំឲ្យកើតបញ្ញាមាន ៣ យ៉ាង គឺ:

១ – បញ្ញាកើតអំពីគិត ;

២ – បញ្ញាកើតអំពីស្ដាប់ ;

៣ – បញ្ញាកើតអំពីចំរើនភាវនា ។

បើបានប្រកបព្រមដោយហេតុទាំង ៣ យ៉ាងនេះ បញ្ញាទើបកើតឡើងគ្រប់គ្រាន់មិនខ្វះខាតឡើយ ។

ឯគ្រឿងប្រកបផ្សំនោះលោកពោលទុកមកមាន ៤ យ៉ាង គឺ:

១ – សេពគប់នឹងលោកដែលប្រព្រឹត្តល្អដោយកាយ - វាចា - ចិត្ត ដែលហៅថា សប្បុរស ;

២ – ស្ដាប់ពាក្យប្រៀនប្រដៅលោកដោយគោរព ;

៣ – ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ;

៤ — ប្រតិបត្តិធម៌ឲ្យសមគួរដល់ពាក្យប្រៀនប្រដៅរបស់លោក ។

**សេពគប់នឹងសប្បុរស** ការសេពគប់ជាកម្លាំងយ៉ាងធំ បើគប់ពាល ៗ នាំឲ្យទុក្ខ គប់សប្បុរសជាហេតុនាំឲ្យកើតផលកើតប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ, ព្រោះលោកប៉ុនប្រសប់ណែនាំប្រៀនប្រដៅបុគ្គលដែលចូលទៅគប់ប្រសព្វនឹងលោកនោះ ឲ្យយល់ច្បាស់ជាំងផ្លូវលោកនិងផ្លូវធម៌ ឲ្យមានស្មារតីនឹករឮកឃើញធម៌ដែលខ្លួនគួរប្រព្រឹត្ត និងមិនគួរប្រព្រឹត្តផង, ឲ្យមានប្រាជ្ញាចេះពិចារណាលៃលកឲ្យស្គាល់បាបបុណ្យគុណទោសផង, ហើយក៏តាំងចិត្តស្ដាប់ឱវាទលោកដោយសេចក្ដីគោរព មិនបណ្ដែតបណ្ដោយចិត្តឲ្យរសាត់ទៅក្នុងអារម្មណ៍ផ្សេង ៗ ដាក់ចិត្តឲ្យមាំក្នុងឱវាទរបស់លោកនោះៗ, លុះស្ដាប់បានហើយក៏ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ហើយក៏ពិចារណាឲ្យស្គាល់ន័យនិងគុណធម៌នោះៗ និងលៃលកទៅតាមទំនងធម៌ថា: ធម៌នេះគួរប្រតិបត្តិ, ធម៌នេះមិនគួរប្រតិបត្តិ, ហើយជ្រើសរើសប្រតិបត្តិឲ្យសមគួរទៅតាមកាលនិងតាមប្រទេសនិងភូមិស្ថានរបស់ខ្លួន និងប្រតិបត្តិឲ្យត្រូវតាមសំនួនរបស់ធម៌មិនឲ្យខុសអំពីគតិរបស់ធម៌ឡើយ ។

ម្យ៉ាងទៀតលោកពន្យល់ថា: បណ្ដាមនុស្សដែលកើតមកក្នុងលោកនេះ បើទុកណាជាមានកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ជាគ្រឿងជំនួយជួយក្នុងកិច្ចការរកស៊ីចិញ្ចឹមជីវិតអំពីដើមខ្លះក៏ពិតមែនហើយ ប៉ុន្តែ

និងធ្វើការងារនោះៗ ឲ្យសម្រេចដោយងាយ ហើយស្រួលបួលមិនឲ្យខុសខូចខាត និងប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសេចក្តីល្អ ដែលជាហេតុនាំឲ្យបានសេចក្តីសុខ-ចំរើននោះ ក៏ត្រូវតែអាស្រ័យសេចក្តីឈ្លៀវឆ្លាសវៃឆ្លាតជំនាញ, ហើយត្រូវជាមនុស្សចេះសង្កេតរកហេតុផល ព្រមទាំងធ្លាប់បានជួបប្រទះឃើញបែបផែន និងប្រវេណីដែលមានមកអំពីដើមផង, ទើបការងារដែលនិងប្រព្រឹត្តនោះបានសម្រេចដោយស្រួលបួលឆាប់រហ័សរួសរាន់ទាន់ចិត្តប្រាថ្នា ។

ឯសេចក្តីឈ្លៀវឆ្លាសវៃឆ្លាតជំនាញក្នុងការងារ ព្រមទាំងកិរិយាមារយាទនិងប្រាជ្ញាជាគ្រឿងសង្កេតរកហេតុរកផល ដែលនឹងកើតឡើងបាននោះ ក៏មកតែអំពីចូលទៅជិតគប់ប្រសព្វនឹងសប្បុរសប៉ុណ្ណោះ ព្រោះហេតុដូច្នោះ សាធុសប្បុរសទាំងឡាយគួរគប់ប្រសព្វនឹងសប្បុរសនេះតែម្យ៉ាង ព្រោះលោកអាចនាំឲ្យចំរើនប្រាជ្ញា ។

**ការស្តាប់ពាក្យប្រៀនប្រដៅលោកដោយគោរព** នោះសេចក្តីអធិប្បាយថា: បុគ្គលគប្បីសន្រ្ទឹមប្រយ័ត្នចិត្តកុំឲ្យពយមាយ ឬកំចាត់បង់នូវចិត្តរវើរវាយរសាប់រសល់កុំឲ្យមាននៅក្នុងសន្តានបាន, ដំកល់ចិត្តឲ្យនឹងនួនប្រុងចាំស្តាប់ពាក្យទូន្មានរបស់លោកជាសប្បុរស ដើម្បីឲ្យបានសម្រេចសម្បត្តិជាលោកិយនិងលោកុត្តរណាមួយ, ឬដើម្បីឲ្យបានចេះចាំច្រើនជាពហុស្សូតឡើង ហើយនិងសំដែងប្រាប់ដល់អ្នកដទៃដោយសេចក្តី

អនុគ្រោះ ឲ្យអ្នកដទៃបានធ្វើការកុសល គ្រាន់ជាឧបនិស្ស័យទៅអនាគតៗ ម្យ៉ាងទៀត បុម្សីទួកទៃដែលលោកគ្រូបានប្រៀនប្រដៅឲ្យខំប្រឹងប្រែងរក ស៊ីចិញ្ចឹមជីវិត ទឹងធ្វើការងារអ្វីៗ ដទៃដែលជារបស់ឥតទោស ឬឲ្យខំ រៀនសូត្រចំណេះវិជ្ជាដែលឥតទោស ក៏ត្រូវកុំប្រហែសធ្វេសក្នុងការស្តាប់ ឲ្យសោះ ព្រោះការតាំងចិត្តស្តាប់មាំជាគ្រឿងចំរើនប្រាជ្ញា ។

**ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា** នោះ ហៅឲ្យខ្លីថា យោនិសោមនសិការៈ គឺគិតយោគ្រិះរិះពិចារណាឲ្យស្គាល់ហេតុនិងផល អាក្រក់ ល្អ ដោយយោបល់ដ៏ប្រពៃ; អធិប្បាយថា: បណ្តាកិច្ចការគ្រប់ ចំពូក ដែលបុគ្គលធ្វើរួចហើយក្តី កំពុងធ្វើក្តី, បម្រុងនឹងធ្វើក្តី, ក៏ត្រូវតែ អាស្រ័យយោនិសោមនសិការៈជាមុនដរាប ទើបការងារទាំងនោះសម្រេច ទៅបានដោយស្រួលមិនខ្ទាំខ្ទង់ឡើយ ; ឯយោនិសោមនសិការៈនោះ មិនមែនជាគួបញ្ញាទេ គ្រាន់តែជាឧបាយជួយឧបត្ថម្ភឲ្យមានប្រាជ្ញាធ្វើ ឆ្លាសវាងវៃស្ទាត់ជំនាញក្នុងការងារនោះៗ ប៉ុណ្ណោះឯង ; ព្រោះមនុស្ស យើង បើកាលណាមានដំណើរទៅកាន់ទីដទៃៗ ហើយបានជួបប្រទះ នឹងវត្ថុអ្វីៗ ឬវិធីបែបផែនដែលគេតាំងទុកក្នុងទីណាមួយ ឬបានរៀន ចំណេះវិជ្ជាណាមួយ, បើមិនខំប្រឹងប្រែងយកចិត្តទុកដាក់ពិចារណាត្រិះ រិះដោយយោបល់ ឲ្យស្គាល់ហេតុផលក្នុងវត្ថុ ឬវិជ្ជានោះៗ ឲ្យសព្វ គ្រប់ទេ ការដែលធ្វើឲ្យឆ្លាសវាងវៃក្នុងកិច្ចការនោះៗ ក៏មិនបានកើតឡើង ;

ឯយោនិសោមនសិការៈនេះ សុំសេចក្តីបានទាំងផ្លូវលោកនិងផ្លូវធម៌ ។ ឯចំណេះវិជ្ជាផ្លូវលោកនោះ គឺត្រូវរៀនឲ្យចេះអក្សរនិងលេខនព្វន្តគណនាជាដើម, ឯវិជ្ជាខាងផ្លូវធម៌ គឺត្រូវរៀនឲ្យចេះព្រះបរិយត្តិធម៌ជាដើម, កាលបើបានរៀនសូត្រវិជ្ជាណាមួយហើយ ក៏ត្រូវតែប្រើគំនិតពិនិត្យពិចារណាឲ្យចេះចាំស្ទាត់ប្រាកដក្នុងចិត្ត ឬបានមើលក្បួនគម្រោដែលអ្នកប្រាជ្ញបានចេញជាវិធីបែបផែនទុកមក ដូចជាសម័យសព្វថ្ងៃនេះត្រូវតែកត់ត្រូសចំណាំទុកក្នុងចិត្ត នូវសេចក្តីត្រង់ណាដែលប្លែកក្អែកប្លែកគំនិត ត្រូវសង្កេតមើលឲ្យឃើញហេតុផល ហើយគិតស្រាវជ្រាវការរកឲ្យទាល់តែចូលចិត្តសេចក្តីនោះសឹមឈប់, យ៉ាងនេះឯង វិជ្ជាដែលរៀននោះទើបនឹងភ្លឺស្វាងរុងរឿងឡើងជាលំដាប់ ៗ តទៅ ។ បើនិយាយខាងផ្លូវធម៌វិញ គឺកាលដែលបានជួបប្រទះវត្ថុជារបស់មានវិញ្ញាណ ឬគតវិញ្ញាណ ក៏ត្រូវតែមានគំនិតត្រិះរិះពិចារណាឲ្យឃើញច្បាស់ថាជារបស់មិនទៀងជាទុក្ខ មិនមែនខ្លួនប្រាណ, យ៉ាងនេះទើបប្រាជ្ញាជាន់ខ្ពស់ដែលលោករាប់បញ្ចូលទៅក្នុងលោកុត្តរបញ្ញានេះកើតឡើងបាន; ហេតុដូច្នោះសាធុសប្បុរសគួរតែបង្កើតយោនិសោមនសិការឲ្យមាននៅក្នុងខន្ធសន្តាន, ព្រោះជាធម៌សំខាន់ខាងធ្វើឲ្យចំរើនប្រាជ្ញា ។

**ប្រតិបត្តិធម៌សមគួរដល់ធម៌** — គុណធម៌នេះជាប់មកពីយោនិសោមនសិការៈ; ព្រោះថាបុគ្គលកាលនឹងប្រតិបត្តិធម៌នោះ លុះតែបានត្រិះរិះពិចារណាឲ្យស្គាល់ហេតុផលសភាវធម៌នោះ ៗ ជាមុនសិន ទើប

នឹងប្រតិបត្តិឲ្យសមគួរដល់កំរិតធម៌នោះៗបាន, កាលបើបុគ្គលប្រតិបត្តិឲ្យត្រឹមត្រូវតាមកំរិតរបស់ធម៌ហើយ រមែងបានជួបប្រទះនឹងសេចក្ដីសុខ សេចក្ដីចំរើនមិនខានឡើយ ។

ចំណែកបុគ្គលដែលប្រព្រឹត្តធម៌ ប៉ុន្តែមិនបានជួបប្រទះនឹងសេចក្ដីសុខដោយបរិបូណ៌ ដោយហេតុបុគ្គលនោះឯងប្រតិបត្តិធម៌មិនសមគួរដល់ធម៌ដែលខ្លួនបានត្រិះរិះឃើញ ព្រោះបុគ្គលខ្លះប្រឹងប្រតិបត្តិធម៌តឹងហួស ខ្លះប្រតិបត្តិធម៌ធូរហួសពេក; ព្រោះតែតឹងហួសធូរហួសយ៉ាងនេះ បានជាមិនបានជួបប្រទះនឹងសេចក្ដីសុខសេចក្ដីចំរើន ដែលជាផលនៃការប្រតិបត្តិនោះៗ ដោយគ្រប់គ្រាន់ឡើយ ។ ឯការដែលប្រតិបត្តិធម៌សមគួរដល់កំរិតរបស់ធម៌នោះ គួរយ៉ាងដូចជាបុគ្គលដែលរក្សាសីល គប្បីសង្រួមប្រយ័ត្នរក្សាសិក្ខាបទដែលខ្លួនបានកាន់កាប់ហើយ កុំឲ្យធ្លុះធ្លាយឬសៅហ្មងសិក្ខាបទណាមួយ ដំណើរនោះ អ្នកប្រតិបត្តិនឹងកើតសេចក្ដីត្រជាក់ចិត្តឥតក្ដៅក្រហាយ ។ ឯការប្រតិបត្តិធម៌សមគួរដល់ធម៌ ដូចសំដែងមកនេះ រមែងបានសេចក្ដីសុខ ទាំងក្នុងជាតិនេះនឹងជាតិខាងមុខ ហើយនឹងបានជាបច្ច័យនៃព្រះនិព្វានជាអវសានជាតិមិនឃ្លាតឡើយ ។

កាលបើសាធុសប្បុរសមានសេចក្ដីប៉ុនប៉ងចង់បានប្រាជ្ញា គួរខំបណ្ដុះដាំផ្សាំប្រាជ្ញាឲ្យកើតឡើង ត្រូវប្រកបផ្សំធម៌ទាំង ៤ នេះឲ្យកើតមានក្នុងសន្ដាន ទើបប្រាជ្ញាកើតចំរើនឡើងជាលំដាប់ ។

**សំដែងមកអំពីធម៌ជាគ្រឿងចំរើនប្រាជ្ញាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។**